# ព្រះវិហារវត្តព្រះធាតុបាស្រី

ព្រះធាតុបាស្រី ឬព្រះធាតុព្រះស្រី ជាឈ្មោះវត្តមួយស្ថិតនៅក្នុងឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ វត្តនេះសាងសង់ឡើងនៅជាប់នឹងបរិវេណប្រាសាទបុរាណ និងជាវត្តមានព្រះវិហារយ៉ាងចំណាស់ ដែលមានមណ្ឌបមួយសង់នៅខាងក្រោយ ប្រកបដោយលក្ខណៈសិល្បៈយ៉ាងវិចិត្រ។ តាមឯកសារមហាបុរសខ្មែរឱ្យដឹងថា អារាមនេះជាបូជនីយដ្ឋានយ៉ាងសំខាន់ក្នុងរាជ្យហ្លួងព្រះស្ដេចកន។ ប៉ុន្តែព្រះវិហារដែលគង់នៅដល់សព្វថ្ងៃនេះ គេដឹងថាកសាងនៅដើមសតវត្សទី២០ រីឯមណ្ឌបខាងក្រោយកសាងក្នុងទសវត្សទី៥០។ ព្រះវិហារនេះ ធ្លាប់បានរុះរើធ្វើបំផ្លាញក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយចាប់ពីទសវត្សទី៨០ គេបានជួសជុលឡើងវិញ ព្រមទាំងលាបថ្នាំ គូរគំនូរ និងកែលម្អរចនាសម្ព័ន្ធនានាជាបន្តបន្ទាប់រហូតមក (រូបលេខ១-៣)។



រូបលេខ១-៣ ព្រះវិហារ និងមណ្ឌបវត្តព្រះធាតុបាស្រីបច្ចុប្បន្ន

ពាក់ព័ន្ធនឹងឈ្មោះ "ព្រះធាតុបាស្រី" ឬ "ព្រះធាតុព្រះស្រី" មានសេចក្ដីតំណាលថា "សម័យថ្ងៃមួយនោះ បណ្ដាអ្នកស្រុកទាំងប៉ុន្មាន ក្រឡេកទៅឃើញព្រះអរហន្តហោះធ្យានលើអាកាស ធ្លាក់មកលិចទៅក្នុងដីបាត់ បែករស្មីជា៧ពណ៌។ អ្នកស្រុកនាំគ្នាឆោឡោជីកដីនោះទៅជ្រាបដល់សម្ដេចចៅពញាអរជូនអង្គកែម ព្រះអង្គទ្រង់សាទរចេញមកឃោសនាអស់ក្រុមការឱ្យជួយជីកដីនោះទៀត ឃើញព្រះបរមសារីរិកធាតុ ហើយក៏ឆោឡោធ្វើសក្ការបូជា ធ្វើព្រះអារាម ធ្វើព្រះវិហារ សីមា ព្រះចេតិយ សុទ្ធសឹងតែពីថ្ម ល្អថ្ងៃថ្លាបញ្ចុះ

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

ព្រះបរមសារីរិកធាតុ រួចតាំងនាមចៅអធិការវត្តនោះជាសម្តេចព្រះសិរីធម្មធាតុ តាំងនាមវត្តនោះហៅវត្តព្រះធាតុ បានជាប់ហៅថាវត្តព្រះស្រី ព្រះធាតុរៀងមក" (រូបលេខ២៨)។[១]



រូបលេខ២៨ ខ្លោងទ្វារវត្តព្រះធាតុបាស្រីបច្ចុប្បន្ន

ទោះជាបែបណាក្តី នៅឆ្នាំ១៩០០ លោក អែម៉ូនីញេ(E. Aymonier)បានកត់ចំណាំថាវត្តនេះឈ្មោះ "វត្តទួលព្រះធាតុ" ស្ថិតក្នុងភូមិ "បាស្រី"។[២] ពាក្យ "ព្រះធាតុ" នោះសោត លោកយល់ឃើញថាជាព្រះសារីរិកធាតុ។[៣] ទន្ទឹមនោះដែរ លោក លុយណេត៍ ដឺ ឡាហ៊ុងគៀរ (Lunet de Lajonquier) ក៏បានសិក្សា និងចុះបញ្ជីបុរាណដ្ឋានក្នុងតំបន់នេះ ហើយលោកបានពិពណ៌នាខ្លីអំពីព្រះវិហារវត្តព្រះធាតុថា ជាសំណង់មានរាងចតុកោណកែង សង់បែរទិសលិច-កើត ជញ្ជាំងឥដ្ឋមានសរសេរបួនជ្រុងទ្រដំបូលពីរថ្នាក់ ដែលមានបង្អួចធំៗរាងបួនជ្រុងនៅតាមជញ្ជាំងចំហៀង និងទ្វារមុខ-ក្រោយ។ លើសពីនេះ លោកថែមទាំងភ្ជាប់រូបភាពនៃព្រះវិហារនោះដែលគេឃើញមានមណ្ឌបមួយរាងបួនជ្រុងនៅខាងក្រោយផង (រូបលេខ២៩)។[៤]



រូបលេខ២៩ វត្តព្រះធាតុបាស្រីផ្អែកតាមឯកសារបារាំង

ចំពោះព្រះវិហារវត្តព្រះធាតុបាស្រីសព្វថ្ងៃ ជាព្រះវិហារសង់អំពីថ្មផ្នែកខាងក្រោម និងគ្រឿងបង្គុំឈើនៅផ្នែកខាងលើ។ ព្រះវិហារនេះ សង់លើខឿនកម្ពស់ប្រហែល១ ម៉ែត្រ ដំបូលប្រក់ក្បឿងស្រកាលេញ ក្នុងទម្រង់ជាវិហារជហ្វា៦។ នៅតាមព្រំដំបូលនីមួយៗ គេបំពាក់ដោយ

[១] អេង សុត ១៩៦៩: ២៨៤

[២] សូមកុំភ្លេចថា ក្នុងភាសាខ្មែរមានពាក្យច្រើនណាស់ដែលនិយាយប្រែប្រួលសំឡេងពី "ព្រះ" ទៅ "បា"។

[៣] E. Aymonier 1900: 283-285

[៤] Lunet de Lajonquier 1902: XXVII

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

នាគជង់ក្តារដូចវិហារបុរាណនានាផ្សេងទៀតដែរ (រូបលេខ២៦-៨)។ រីឯរង់ស្បូវជុំវិញសុទ្ធសឹងឆ្លាក់អំពីឈើ ប្រកបដោយក្បាច់យ៉ាងវិចិត្ររស់រវើក។ សូមបញ្ជាក់ថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេបានរុះរើព្រះវិហារនេះ យកធ្វើជាជម្រកសម្រាប់អ្នក ១៧ មេសា។[៩]



រូបលេខ២៦ ព្រះវិហារមើលពីមុខ



រូបលេខ២៧ ព្រះវិហារសព្វថ្ងៃមើលពីមុខ

(រូបថត៖ វត្តព្រះធាតុបាស្រី, ឆ្នាំ២០១៧)



រូបលេខ២៨ ព្រះវិហារមើលពីចំហៀង

ចំណែកឯហោជាង់ខាងមុខនិងខាងក្រោយនៃព្រះវិហារនេះ គេរចនាលម្អដោយក្បាច់ភ្ញីទេសឆ្លាក់លើផ្ទៃស៊ីម៉ងត៍យ៉ាងរស់រវើក រំលេចព័ទ្ធជុំវិញដើងពានតម្កល់ព្រះខ័ន និងម្កុដ ដែលមានពន្លឺរង្សីនៅកំពូល អមដោយឆ័ត្ររួតមួយគូក្នុងរង្វង់កម្រង់ស្លឹកឈើ។ រូបនេះហាក់ស្រដៀងនឹងព្រះរាជសង្ហារស្តេចផែនដី តែពុំមានរូបរាជសីហ៍ និងគជសីហ៍អមសងខាង (រូបលេខ២៩-១០)។ ទំនងដោយហេតុដូច្នេះ និងដោយសារស្នាកស្នាមប្រវត្តិសាស្ត្រ ព្រមទាំងការសម្គាល់លើសញ្ញាព្រះរាជសង្ហារនៅលើខ្លោងទ្វារខាងមុខ ទើបគេចាត់ទុកវត្តនេះ គឺជាអតីតអារាមហ្លួង។

---

[៩] ផេង ពង្សរ៉ាស៊ី ២០០១: ៦-១១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត





រូបលេខ៩-១០ ក្បាច់លម្អលើហោជាងខាងមុខ និងខាងក្រោយ

ចំពោះរចនាសម្ព័ន្ធខាងក្រោម នៅផ្នែកខាងក្រៅ គឺមានសសរបេតុងមូលធំៗចំនួន៣២ដើម ព័ទ្ធជុំវិញបាំងសាច។ ផ្នែកខាងក្នុងមានសសរបេតុងមូលចំនួន១៦ដើមរត់ត្រង់ជាពីរជួរអមសងខាងព្រះដីរ៍ (រូបលេខ១១-១២)។ សសរទាំងអស់នេះ មាននាទីទ្រគ្រឿងបង្គុំ និងពិតាននៅផ្នែកខាងលើ។ ប៉ុន្តែពិតានព្រះវិហារនេះ គឺជាពិតានឈើដែលគេប្រើក្តារក្រាលនៅលើក្បាលសសរត្រង់លើល្វែងគ្រឹះតែប៉ុណ្ណោះ។ នៅលើចន្លោះរបៀង គេទុកឱ្យនៅលំហទំនេរនិងស្រឡះ អាចមើលឃើញដល់ផ្ទោង ផ្ទាន ដៃរណែង និងក្បឿងដំបូល។ ចំណែកឯនៅតាមជញ្ជាំងចំហៀង គេធ្វើឱ្យមានបង្អួចស្រឡះៗធំៗម្ខាង៩ ដែលអនុញ្ញាតឱ្យពន្លឺ និងខ្យល់ចេញចូលយ៉ាងល្អ។ នៅជញ្ជាំងខាងមុខ និងខាងក្រោយ គេធ្វើឱ្យមានទ្វារម្ខាង២។





រូបលេខ១១-១២ ក្បាច់លម្អលើហោជាងខាងមុខ និងខាងក្រោយ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

យោងតាមចារឹកខាងក្រោយបល្ល័ង្ក គេដឹងថាព្រះវិហារដីរ៍ធំខាងក្នុងព្រះវិហារសាង នៅក្នុងឆ្នាំ១៩៨១។ គេសាងឡើងក្នុងកាយវិហារផ្ចាញ់មារ និងមានរូបនាងគង្ហីងផុសឡើង នៅក្រោយបល្ល័ង្ក (រូបលេខ១៣-១៤)។ ការឆ្លាក់បង្ហាញត្រង់នេះ ស្តែងឱ្យឃើញច្បាស់តាម ពុទ្ធប្រវត្តិនៅត្រង់ពេលដែលព្រះអង្គគង់លើបល្ល័ង្ករតន៍ ហើយមានក្រុងមារលើកទ័ពមក ច្បាំង។ សិល្បៈត្រង់នេះ ហាក់គួរឱ្យពិចារណាក្រៃលែង ដ្បិតពុទ្ធសាសនាក្នុងសង្គមខ្មែរ តែងមានលើកឈុតនេះមកបង្ហាញប្លែកៗទាំងសិល្បៈសម្តែង គំនូរ និងចម្លាក់។






រូបលេខ១៣-១៤ សសរបាំងសាច (ខាងក្រៅ) និងសសរផ្នែកខាងក្នុងព្រះវិហារ

គំនូរនៅលើជញ្ជាំង និងពិតានព្រះវិហារនេះ ប្រហែលគូរក្នុងរវាងទសវត្សទី៩០។ នៅពិតានគេគូរបង្ហាញផ្ទាំងផ្សេងៗដូចជា ព្រះពុទ្ធប្រាំព្រះអង្គ ពពួកទេវតា ព្រះអាទិត្យ និង ព្រះចន្ទ្រ។ ប៉ុន្តែទន្ទឹមនឹងនោះ គេឃើញមានរូបរាហ៊ូមួយយ៉ាងធំគួរឱ្យកត់សម្គាល់គូរនៅ ចន្លោះព្រះអាទិត្យ និងព្រះចន្ទ្រ (រូបលេខ១៥)។ ចំណែកឯគំនូរនៅតាមជញ្ជាំងគឺគូររៀបរាប់ រឿងពុទ្ធប្រវត្តិនៅជួរខាងលើ និងរឿងជាតកនៅជួរខាងក្រោម។ សាច់រឿងគំនូរពុទ្ធប្រវត្តិ ចាប់ចេញពីត្រង់ជញ្ជាំងខាងមុខព្រះដីរ៍ ដែលបង្ហាញពីព្រះអង្គបរិនិព្វាន (រូបលេខ១៦)។ ត្រង់ជញ្ជាំងខាងមុខនេះដែរ គេឃើញមានផ្តែរមួយបិទភ្ជាប់ជញ្ជាំង ទ្រដោយសសរពេជ្រ ពីរដើម (រូបលេខ១៧)។ តាមការសង្កេត ផ្តែរនេះទំនងយកចេញពីប្រាសាទណាមួយក្នុង ចំណោមប្រាសាទទាំងពីរដែលស្ថិតនៅខាងមុខព្រះវិហារ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១៥ គំនូរលើពិតាន



រូបលេខ១៦ គំនូរព្រះបរិនិព្វានលើជញ្ជាំងខាងមុខ



រូបលេខ១៧ ផ្តែរប្រាសាទរៀបភ្ជាប់ជញ្ជាំងត្រង់ក្រោមគំនូរព្រះបរិនិព្វាន

ដោយឡែក ចំពោះមណ្ឌបខាងក្រោយព្រះវិហារ គេដឹងថាកសាងនៅក្នុងរវាងទសវត្សទី៥០ ពោលគឺកសាងក្រោយព្រះវិហារមួយរយៈឆ្ងាយ។ ប៉ុន្តែសំណង់ទាំងពីរ សង់លើខឿនតែមួយ និងមានសន្ទឹកសីមាព័ទ្ធរួមជុំវិញចំនួន៨ សន្ទឹក។ កំពូលមណ្ឌប គេសង់ឡើងឱ្យមានរាងស្រួចខ្ពស់ហួសព្រះវិហារ ព្រមទាំងមានក្បាច់រចនា និងមុខព្រហ្មនៅត្រង់លើកំពូល។ មណ្ឌបនេះ មានច្រកចូលទាំងបួនទិស ដោយច្រកខាងមុខ ភ្ជាប់នឹងជញ្ជាំងព្រះវិហារផ្នែកខាងក្រោយ (រូបលេខ១៨)។ នៅត្រង់លើទ្វារភ្ជាប់នឹងព្រះវិហារនេះ គេឃើញមានផ្តែរ និងសសរពេជ្រប្រាសាទបុរាណដែរ (រូបលេខ១៩)។ លើសពីនេះនៅផ្នែកខាងក្នុងមណ្ឌប គេតម្កល់ព្រះពុទ្ធរូបនៅជាប់ជញ្ជាំងខាងក្រោយ ហើយនៅត្រង់កណ្តាលនៃមណ្ឌបនោះ គេដាក់តម្កល់ព្រះថែនមួយធំ ធ្វើអំពីថ្មភក់ កម្ពស់ត្រឹមចង្កេះ (រូបលេខ២០)។ រីឯនៅតាមជញ្ជាំង គេគូរអន្ទើខ្លះក្នុងពុទ្ធប្រវត្តិ រឿងវេស្សន្តរ និងទិដ្ឋភាពល្បែងរបាំខ្មែរ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១៨-១៩ មណ្ឌប ព្រះពុទ្ធបដិមាតម្កល់នៅខាងក្នុង និងព្រះថែនថ្មភក់



រូបលេខ២០-២២ គំនូរពុទ្ធប្រវត្តិ ជាតក និងក្រុមភ្លេងបុរាណគូរលើជញ្ជាំងខាងក្នុងមណ្ឌប

សរុបមក តាមរយៈលក្ខណៈសំណង់ និងស្លាកស្នាមវត្ថុសិល្បៈ គេអាចយល់បានថា ព្រះវិហារវត្តព្រះធាតុបាស្រី ជាសំណង់ដើមសតវត្សទី២០ ដែលកសាងឡើងតាមលំនាំសំណង់ដើម នៅលើបុរាណដ្ឋានចាស់។ លក្ខណៈព្រះវិហារដែលមានមណ្ឌបខាងក្រោយបែបនេះ ហាក់អាចសិក្សាពិចារណាប្រៀបធៀបនឹងសំណង់ពុទ្ធសាសនាបុរាណផ្សេងទៀត ដូចព្រះវិហារវត្តនគរបាជ័យជាដើម។ លើសពីនេះ គេគួរមើលបន្ថែមទៅលើសំណង់ពុទ្ធសាសនាផ្សេងៗទៀត ដែលតែងយកប្រាសាទ ឬសាងចេតិយធំៗនៅក្បែរព្រះវិហារ៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ផេង ពង្សរ៉ាស៊ី

២០០១, "វាលពិឃាតនៅស្រុកអូររាំងឪ", *ស្វែងរកការពិត,* លេខ២៣, ទំ.៦-១១, មជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ

អេង សុត

១៩៦៩, *មហាបុរសខ្មែរ,* លេខ១៨, ភ្នំពេញ

Etienne Aymonier

1900, *Le Cambodge; Le Royaume Actuel,* Ernest Leroux, Paris

Lunet de Lajonquier

1902, *Inventaire Archéologique de l'Indo-Chine: Monuments du Cambodge,* Vol. IV, Ernest Leroux, Paris

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត